ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................................

**សុន្ទរកថាស្វាគមន៍**
**ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ**
នៅសាលសន្និសីទចតុមុខ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩

ជាបឋម ខ្ញុំបាទសូមគោរព :

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា រដ្ឋសភា និងព្រឹទ្ធសភា ជាទីគោរព
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិករដ្ឋាភិបាល ជាទីគោរព
- ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត និងភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា តំណាងអាជ្ញាធរដែនដី និង តំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាទីស្នេហា

ថ្ងៃនេះ គឺជាទិវាប្រវត្តិសាស្ត្រមួយ ប្រកបដោយក្តីរំភើបរីករាយ និងកិត្តិយសខ្ពង់ខ្ពស់បំផុត ដែលធនាគារជាតិនៃកម្ពុជា បានរៀបចំប្រារព្ធពិធីរំឭកខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ពិធីដ៏មហោឡារិកនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីអបអរសាទរចំពោះសមិទ្ធផលរីកចម្រើនរបស់វិស័យធនាគារ ដែលបានរួមចំណែកកសាង និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក្នុងរយៈពេល ៣០ឆ្នាំ បន្ទាប់ពីថ្ងៃមហាជ័យជំនះ ៧ មករា ១៩៧៩ ។

តាងនាមឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ និងក្នុងនាមខ្ញុំបាទផ្ទាល់ សូមគោរពស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះ **សម្តេចនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតឱកាសដ៏មមាញឹក និងផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីនេះ ។ វត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចនាយករដ្ឋមន្ត្រី** នៅពេលនេះ គឺជាការលើកទឹកចិត្តមួយដ៏ខ្លាំងក្លាបំផុត សម្រាប់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា និងបានញ៉ាំងឱ្យអង្គពិធីទាំងមូលកាន់តែមានភាពឱឡារិក អធិកអធម សប្បាយរីករាយ និងមានអត្ថន័យជ្រាលជ្រៅជាប្រវត្តិសាស្ត្រថែមទៀត ។


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ខ្ញុំសូមស្វាគមន៍ផងដែរ ចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល អាជ្ញាធរដែនដីរាជធានី-ខេត្ត និងតំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានឆ្លៀតពេលអញ្ជើញចូលរួមក្នុងពិធីនាពេលនេះ ។

**សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី !**

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមគោរពជម្រាបជូនពីដំណើរវិវត្តន៍រីកចម្រើននៃធនាគារជាតិនៃកម្ពុជា និងគោលបំណងនៃការរៀបចំខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ ដូចតទៅ :

ជាប្រវត្តិជាក់ស្តែង ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ ក្រោយពីបានឯករាជ្យពីអាណានិគមនិយមបារាំង ប៉ុន្តែ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបប្រល័យពូជសាសន៍ ប៉ុល ពត បានចូលមកដល់ បានកាប់សម្លាប់ប្រជាជនស្លូតត្រង់ បំផ្លាញរចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម ដូចជា សាលារៀន មន្ទីរពេទ្យ ស្ថាប័នរដ្ឋបាល អគារពាណិជ្ជកម្ម និងវត្តអារាមចោល និងបានប្រែក្លាយប្រទេសកម្ពុជាទៅជាសង្គមទាសភាពបុព្វកាល ។ ចំណែកឯប្រព័ន្ធរូបិយវត្ថុ និងប្រព័ន្ធធនាគារទូទាំងប្រទេសត្រូវបានបំផ្លាញចោល អគារធនាគារជាតិនៃកម្ពុជាត្រូវបានកម្ទេច រូបិយវត្ថុជាតិត្រូវបានឈប់ប្រើប្រាស់ និងលុបបំបាត់កម្មសិទ្ធិឯកជន ព្រមទាំងបានលុបបំបាត់ទីផ្សារមិនឱ្យមានដំណើរការ តែក្នុងរយៈពេលមួយថ្ងៃប៉ុណ្ណោះ ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមាន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម សម្តេចអគ្គមហាពញាចក្រី ហេង សំរិន និង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានដឹកនាំកម្លាំងអ្នកស្នេហាជាតិទាំងអស់ គាំទ្រដោយកងទ័ពស្ម័គ្រចិត្តវៀតណាម រំដោះប្រជាជន និងសង្គ្រោះប្រទេសជាតិមាតុភូមិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ ក្រោយថ្ងៃរំដោះ សាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានចាប់បដិសន្ធិឡើង ដើម្បីបំពេញតួនាទីបន្តពីរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក្នុងការការពារអាយុជីវិតប្រជាជននិងទឹកដីផង ការពារការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ផង ដោះស្រាយគ្រោះទុរភិក្សជូនប្រជាជនទូទាំងប្រទេស និងបង្កលក្ខណៈឱ្យប្រជាជនវិលត្រឡប់ទៅជួបជុំសាច់ញាតិគ្រួសារ និងវិលទៅស្រុកកំណើតវិញ ជាពិសេស បានរៀបចំកសាងរដ្ឋអំណាចប្រជាជនគ្រប់ផ្នែកនិងគ្រប់ថ្នាក់ពីបាតដៃទទេ ដើម្បីគ្រប់គ្រងទឹកដី និងកសាងមាតុភូមិកម្ពុជាឡើងវិញលើគ្រប់វិស័យ ក្នុងបំណងដើម្បីឱ្យប្រជាជនរស់នៅក្នុងសុខសន្តិភាព និងការអភិវឌ្ឍ ដូចសព្វថ្ងៃនេះ ។ អាស្រ័យហេតុនេះហើយ បានជាប្រជាជនទូទៅចាត់ទុកទិវាមហាជ័យជំនះជាប្រវត្តិសាស្ត្រ ៧ មករា គឺជាថ្ងៃកំណើតទី២របស់ខ្លួន ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ ជាធនាគារកណ្តាលរបស់ប្រទេស មានឈ្មោះហៅថា "**ធនាគារជាតិនៃប្រជាជនកម្ពុជា**" ។ រយៈពេល ៦ខែបន្ទាប់ ដើម្បីធានានូវអធិបតេយ្យភាព និងឯករាជ្យភាពខាងរូបិយវត្ថុ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដោយ

មានកិច្ចសហការគាំទ្រពីប្រទេសជាមិត្តផងនោះ ប្រាក់រៀលថ្មីត្រូវបានបោះផ្សាយនិងដាក់ឱ្យធ្វើចរាចរឡើងវិញផងដែរ ដើម្បីធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចជាតិរស់ឡើងវិញ ដូចជា ការផ្តល់ឥណទានដល់ក្រុមសាមគ្គីបង្កបង្កើនផល និងសហគ្រាសរដ្ឋ មធ្យោបាយការដោះដូរទំនិញ និងការទូទាត់ពាណិជ្ជកម្ម ជាដើម ។ ធនាគារជាតិនៃប្រជាជនកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ឥណទាន ដើម្បីស្តារសកម្មភាពសេដ្ឋកិច្ច ដូចជា ការស្តារដីកសិកម្ម ការដាំដុះ សិប្បកម្ម សកម្មភាពនេសាទ អាជីវកម្មដំណាំកៅស៊ូ និងឈើជាដើម ។ល។ ជាពិសេស គឺការប្រមូលទិញកសិផល ដែលធ្វើឱ្យផលិតកម្មកសិកម្មមានការរីកចម្រើនយ៉ាងឆាប់រហ័ស ។ ការបោះប្រាក់រៀលឱ្យចរាចរឡើងវិញនេះ ត្រូវបានប្រជាជនទូទាំងប្រទេសអបអរសាទរ និងស្វាគមន៍យ៉ាងខ្លាំង ។ នេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ផងដែរ ក្រោយថ្ងៃមហាជ័យជំនះ ៧ មករា ឆ្នាំ១៩៧៩ ។

នៅមុនឆ្នាំ១៩៨៩ យើងអនុវត្តរបបសេដ្ឋកិច្ចផែនការ ។ ចាប់ពីឆ្នាំ១៩៨៩ រដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ចពីរបបសេដ្ឋកិច្ចផែនការ ទៅជារបបសេដ្ឋកិច្ចទីផ្សារសេរី បន្ទាប់មក ប្រកាន់យករបបសេដ្ឋកិច្ចផែនការគួបផ្សំទីផ្សារ ។ ក្នុងរយៈពេលនេះ រដ្ឋបានទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លី និងមធ្យោបាយដឹកជញ្ជូន និងបានធ្វើកំណែទម្រង់សហគ្រាសរដ្ឋ ជាដើម ។ ទន្ទឹមនឹងនេះ រដ្ឋបានបំបែកមុខងារបេឡាថវិការដ្ឋពីធនាគារជាតិនៃកម្ពុជា និងបានបង្កើតរតនាគារជាតិឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងហិរញ្ញវត្ថុ ។ ចំណែកឯប្រព័ន្ធធនាគារវិញ ក៏បានចាប់ផ្តើមធ្វើកំណែទម្រង់ផងដែរ ដោយឱ្យធនាគារខេត្ត-ក្រុងប្តូរឈ្មោះទៅជាធនាគារឯកទេសខេត្ត-ក្រុង ធ្វើសកម្មភាពតាមបែបស្វ័យាភិបាលសេដ្ឋកិច្ចនៅក្នុងដែនដីរបស់ខ្លួន ។

នៅឆ្នាំ១៩៩២ ច្បាប់ស្តីពីគ្រឹះស្ថានរូបិយវត្ថុ ប្តូរឈ្មោះ **ធនាគារជាតិនៃប្រជាជនកម្ពុជា** ទៅជា **ធនាគារជាតិនៃកម្ពុជា** រហូតដល់សព្វថ្ងៃ និងបានបើកទូលាយអាជីវកម្មលើវិស័យធនាគារ ដោយអនុញ្ញាតឱ្យធនាគារពាណិជ្ជបង្កើតឡើងក្រោមច្បាប់ក្នុងស្រុក ឬក្រោមទម្រង់ជាសាខាធនាគារបរទេស ។

ក្នុងរយៈពេលនេះ វិស័យធនាគារចាប់ផ្តើមរីកចម្រើនគួរឱ្យកត់សម្គាល់ ។ បន្ទាប់មក នៅឆ្នាំ១៩៩៦ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ត្រូវបានអនុម័តដោយរដ្ឋសភា ដើម្បីពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងពង្រឹងតួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ ។ ច្បាប់នេះ បានកំណត់តួនាទីធនាគារជាតិនៃកម្ពុជា ជាធនាគារកណ្តាលនៃប្រទេស និងជាអាជ្ញាធរអាណាព្យាបាលលើប្រព័ន្ធធនាគារទាំងមូល ហើយមានបេសកកម្មចម្បង គឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថិរភាពថ្លៃ ឆ្ពោះទៅគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

នៅឆ្នាំ១៩៩៩ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបានអនុម័ត ដើម្បីធ្វើជាមូលដ្ឋានគតិយុត្តក្នុងការគ្រប់គ្រង និងត្រួតពិនិត្យសុខភាពគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ។ បន្ទាប់មកនៅឆ្នាំ២០០១ ដើម្បីបន្តពង្រឹងសុខភាពប្រព័ន្ធធនាគារ និងចង្អុលទិសអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជា ទើបរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយកចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ធ្វើជាមាគ៌ា និងកំណត់

ដំណាក់កាលជាជំហាន១ សម្រាប់បន្តពង្រឹង និងអភិវឌ្ឍវិស័យធនាគារនៅកម្ពុជាឱ្យមានសុខភាពល្អ និងមានប្រសិទ្ធភាពថែមទៀត ។ បន្ទាប់មក ចក្ខុវិស័យនេះ ត្រូវបានរាជរដ្ឋាភិបាលធ្វើបច្ចុប្បន្នកម្មឱ្យទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ដើម្បីរំកិលទៅអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយនូវកម្មវិធីផ្សេងៗទៀត ។

បច្ចុប្បន្នវិស័យធនាគារនៅកម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងផ្នែកវិសាលភាព និងទំហំប្រតិបត្តិការ និងបានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ទន្ទឹមនេះ ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ ត្រូវបានមជ្ឈដ្ឋានជាតិ និងអន្តរជាតិទទួលស្គាល់ថា ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ បច្ចុប្បន្នវិស័យនេះ មានការរីកចម្រើន និងមានភាពរឹងមាំ ទាំងរចនាសម្ព័ន្ធ និងទំហំប្រតិបត្តិការរហូតដល់ជនបទ បន្ទាប់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសយកឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុរួចមក ។ ប្រជាជនទូទៅបានយល់ដឹងពីវប្បធម៌ឥណទាន ពីផលប្រយោជន៍នៃការប្រើប្រាស់ឥណទាន និងការទទួលបានឥណទានយកទៅប្រើប្រាស់ ដើម្បីកែប្រែជីវភាពរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង ។

**សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី !**

គោលបំណងសំខាន់នៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ គឺដើម្បីអបអរសាទរពីស្នាដៃ និងសមិទ្ធផលរីកចម្រើននៃវិស័យធនាគារ ដែលបានចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈការខិតខំពង្រឹងស្ថិរភាពថ្លៃ និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ ។ សមិទ្ធផលទាំងនេះ កើតចេញមកពីការខិតខំប្រឹងប្រែងបំពេញការងារ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ និងដោយមានការចូលរួមសហការល្អពីក្រសួង-ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងមានកិច្ចសហការគាំទ្រពីសំណាក់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជាដើម ។ ជាពិសេស ដោយសារភាពអំណោយផលពីនយោបាយឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបាននាំមកនូវស្ថិរភាពនយោបាយ និងសន្តិភាព១០០% នៅទូទាំងប្រទេស ទើបមានការអភិវឌ្ឍលើគ្រប់វិស័យដូចសព្វថ្ងៃនេះ ក្នុងនោះវិស័យធនាគារក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ។

ជាថ្មីម្តងទៀត តាងនាមឱ្យថ្នាក់ដឹកនាំ ក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស និងខ្ញុំបាទ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត និងសូមដឹងគុណជាអនេកប្បការចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ដែលតែងតែបានផ្តល់អនុសាសន៍ណែនាំប្រកបដោយគតិបណ្ឌិតខ្ពង់ខ្ពស់ដល់ខ្លួនខ្ញុំបាទផ្ទាល់ជាប់ជាប្រចាំ ក្នុងការកំណត់និងដឹកនាំនយោបាយរូបិយវត្ថុ ឆ្ពោះទៅរក្សាស្ថិរភាពថ្លៃ និងស្ថិរភាពហិរញ្ញវត្ថុ សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

ប្រកបដោយចីរភាព និងជោគជ័យ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ហើយពេលនេះ **សម្តេចនាយករដ្ឋមន្ត្រី** ក៏បានផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីដ៏មានសារៈសំខាន់ជាប្រវត្តិសាស្ត្រនេះទៀត ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះ **ឯកឧត្តម ចាន់ ភិន ឯកឧត្តម ចា រៀង និង ឯកឧត្តម ថៅ ប៉េងលាត** ជាអតីតទេសាភិបាល ដែលបានរួមកសាងមូលដ្ឋានគ្រឹះ ដឹកនាំធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលកន្លងមកមុនខ្ញុំបាទ និងថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ-អន្តរជាតិ ដែលបានរួមចំណែកកសាង និងអភិវឌ្ឍប្រព័ន្ធធនាគារ ឱ្យមានការរីកចម្រើនរហូតមកដល់សព្វថ្ងៃ ។ ទាំងនេះ គឺជាសមិទ្ធផលជាទីមោទនៈរបស់យើងទាំងអស់គ្នា ដែលបានរួមសាមគ្គីគ្នាកសាងជូនប្រទេសជាតិ និងមាតុភូមិរបស់យើង ។

ខ្ញុំសូមថ្លែងអំណរគុណ និងជូនពរចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ដែលអញ្ជើញចូលរួមក្នុងពិធីនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ សូមគោរពជូនពរ **សម្តេចនាយករដ្ឋមន្ត្រី និងលោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រី សូមមានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាឈ្លាសវៃ និងទទួលបានជ័យជំនះគ្រប់ភារកិច្ច ដើម្បីបន្តដឹកនាំយើងខ្ញុំ ប្រជាជនកម្ពុជា និង ប្រទេសជាតិឆ្ពោះទៅរកភាពសុខដុមរមនា សម្បូរសប្បាយ និងមានការអភិវឌ្ឍប្រកបដោយចីរភាព ។

ដើម្បីឱ្យអង្គមិទ្ទិញរបស់យើង បានជ្រាបពីខ្លឹមសារសំខាន់ និងសមិទ្ធផលរីកចម្រើនដែលវិស័យធនាគារបានចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងរយៈពេល៣០ឆ្នាំ កន្លងមកនេះ ខ្ញុំបាទមានកិត្តិយសសូមគោរពអញ្ជើញ **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាមានប្រសាសន៍ និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ដើម្បីឱ្យយើងខ្ញុំយកទៅធ្វើជាមាគ៌ាអនុវត្តការងារនៅពេលអនាគត ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។ សូមគោរពអញ្ជើញ ។

**សូមអរគុណ**